ចូលផ្ទះដើម្បីកុំអោយឪពុកម្ដាយវាសួរ ។ នៅពេលទៅដល់មាត់ទ្វារបន្ទប់ស្រាប់តែណារិនឮសំលេងស្រែកច្រៀងចេញពីបន្ទប់ :

"យើងជាកុមារ ត្រូវខំសិក្សា កុំគិតដើរលេង ខំអានសរសេរ ពេលយប់មុនគេង ថ្ងៃមិនដើរលេង យើងទៅសាលា" ។

ឮដូចនោះ ណារិនក៏លបមើល ស្រាប់តែឃើញ ប៊ិច សៀវភៅ និងខ្មៅដៃកំពុងតែរាំច្រៀងលេង ។ ណារិនរំភើបចិត្តណាស់



វាក៏រត់ចូលទៅ ។ ពេលនោះ ប៊ិច ខ្មៅដៃ និងសៀវភៅក៏ឈប់រាំ ។ ណារិននិយាយទៅកាន់អ្នកទាំងនោះ "ម្ដេចក៏ឯងទាំងអស់គ្នាឈប់រាំ ច្រៀងអ៊ីចឹង ?"

ប៊ិចឆ្លើយ : "ពួកយើងជាអ្នករៀនសូត្រ យើងមិនចូលចិត្តអ្នកដើរលេងគេចសាលានោះទេ ។ បើចង់អោយពួកយើងរាំច្រៀង ទាល់តែសិលាញ់ទៅសាលារៀន" ។

ណារិនងក់ក្បាលយល់ព្រម ។ ស្អែកឡើង



ណារិនក្រោកពីព្រលឹមទៅសាលារៀន ប៊ិច ខ្មៅដៃ និងសៀវភៅដើរតាមពីក្រោយដោយច្រៀងរាំផង ។ ណារិនសប្បាយចិត្តណាស់ ក៏ច្រៀងរាំតាម ។ លុះទៅដល់សាលារៀន មិត្តភក្តិរបស់ណារិនឃើញរឿងអស្ចារ្យបែបនោះ ក៏រត់មកជួយច្រៀងគ្រប់ៗគ្នាយ៉ាងសប្បាយរីករាយ ។

